តុលាការកំពូល និងមហាអយ្យការ
អមតុលាការកំពូល
លេខ ២៤៥/០៥.តកក.មទ

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

## ប្រធានតុលាការកំពូល

**<u>ជម្រាបមក</u>**

**លោក ឡុង ដារ៉ា ជាមេធាវីនៅការិយាល័យ**

**លេខ៣៥CD ផ្លូវ២៧១ សង្កាត់ទឹកថ្លា ខណ្ឌឫស្សីកែវ ក្រុងភ្នំពេញ**

**<u>កម្មវត្ថុ</u>:** អំពីសំណើសុំបកស្រាយលិខិតលេខ៤១៩ មកក.សររ ចុះថ្ងៃទី១៦-១១-២០១៥ របស់តុលាការកំពូល ។

**<u>យោង</u>:** លិខិតលេខ៥០/០៥ មធ ចុះថ្ងៃទី០៥-៩-២០០៥ របស់លោក ។

លិខិតលេខ៤១៩ តកក.សររ ចុះថ្ងៃទី១៦-១១-២០០៤ របស់តុលាការកំពូលគឺជាលិខិតឆ្លើយតបទៅនឹងលិខិតលេខ៨៥២/៩៥១-០៤ ចុះថ្ងៃទី២៧-១០-២០០៤ របស់លោកញាណ សុវណ្ណ ចៅក្រមតុលាការក្រុងភ្នំពេញ ដែលបានស្នើសុំការណែនាំស្តីពីការកំណត់បទល្មើសក្នុងការមិនគោរពសាលដីការដ្ឋប្បវេណីលេខ១៦៦ ចុះថ្ងៃទី០៥-០៨-២០០៤ របស់តុលាការកំពូល ។ ការរំលោភ ប្រឆាំង រារាំង ឬមិនអនុវត្តតាមសេចក្តីសម្រេចស្ថាពររបស់តុលាការរដ្ឋប្បវេណី ពុំទាន់មានច្បាប់ណាតម្រូវអោយផ្តន្ទាទោសទេ ។

ប៉ុន្តែក្នុងការអនុវត្តសាលក្រម សាលដីកា ឬសេចក្តីសម្រេចដទៃទៀត បើមានលេចចេញនូវបទល្មើសផ្សេងៗ ដែលមានចែងក្នុងច្បាប់ ដូចជាអំពើលួច រំលោភទំនុកចិត្ត ប្លន់ បង្ករបួសស្នាម មនុស្សឃាដ រំលោភលើសិទ្ធិបុគ្គល ឬ បើមានអំពើប្រឆាំងដីកា សាលក្រម សាលដីការបស់តុលាការ ក្នុងរឿងព្រហ្មទណ្ឌ អយ្យការ និងតុលាការត្រូវចោទប្រកាន់ និងផ្តន្ទាទោសតាមអំពើដែលបានប្រព្រឹត្តនេះ ពីព្រោះបទល្មើសទាំងនេះមានចែងនៅក្នុងច្បាប់ហើយ ។

សូមលោកទទួលនូវការរាប់អានពីខ្ញុំ ។

ធ្វើនៅភ្នំពេញ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០០៥

**ឌិត មុន្ទី**

<u>ចម្លងជូន</u>

-គ្រប់តុលាការខេត្ត ក្រុង
-ឯកសារ